ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ
លេខ ..០០៨....សរ.ករ.គ...../គ.ជ.វ.វ

រាជធានីភ្នំពេញ ថ្ងៃទី..២២.....ខែ..[illegible]....ឆ្នាំ២០០៨

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមគាំទ្រថ្នាក់ស្រុក ខណ្ឌ

---

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន
## គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៩៥ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមគាំទ្រថ្នាក់ស្រុក ខណ្ឌ ដែលស្ថិតនៅក្រោមលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីទទួលខុសត្រូវក្នុងការគ្រប់គ្រង គាំទ្រ និងសម្របសម្រួលដល់ការអនុវត្តគម្រោងនានា ដែលពាក់ព័ន្ធនឹងការពង្រឹងរចនាសម្ព័ន្ធ តួនាទី មុខងារ និងសមត្ថភាពថ្នាក់ស្រុក ខណ្ឌ ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **លេខ ទី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- | ឯកឧត្តម **ទ៉ាន់ ចំរើន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| ៣- | លោក **អែវ ម៉ុនថុល** | ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |
| ៤- | លោក **ចែម ឧត្តរការ** | ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ | ជាសមាជិក |
| ៥- | លោក **ឌី សុភផាន** | ប្រធាននាយកដ្ឋានកិច្ចនយោបាយ | ជាសមាជិក |
| ៦- | លោក **សេខ យូអ៊ាន់** | ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៧- | លោក **ចាន់ សុធា** | អនុប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៨- | លោក **កុយ សារឹម** | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ | ជាសមាជិក |
| ៩- | លោក **ហុង ស៊ីលីន** | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ | ជាសមាជិក |
| ១០- | លោក **សរ គីនីរ៉ា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ | ជាសមាជិក |
| ១១- | លោក **យ៉ុរ ម៉េងស៊ាន** | ប្រធានការិយាល័យរដ្ឋបាល | ជាសមាជិក |
| ១២- | លោក **ម៉ុន ណារុំ** | ប្រធានការិយាល័យសរុប និងរដ្ឋបាល | ជាសមាជិក |
| ១៣- | លោក **ស្រ៊ា រតនៈ** | អនុប្រធានការិយាល័យគ្រប់គ្រងខេត្ត ក្រុង | ជាសមាជិក |
| ១៤- | លោក **ស សុគន្ធ** | អនុប្រធានការិយាល័យផែនការ | ជាសមាជិក |
| ១៥- | លោក **ម៉ក់ ចាន់តារា** | មន្ត្រីនាយកដ្ឋានរដ្ឋបាលទូទៅ | ជាសមាជិក |
| ១៦- | លោក **ឡេង រ៉ាវុធ** | មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | ជាសមាជិក |
| ១៧- | លោក **សួន សរិទ្ធ** | មន្ត្រីនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |
| ១៨- | លោក **ឈាង ផាន់ណារ៉ា** | មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | ជាសមាជិក |

**ប្រការ២.-**

ក្រុមគាំទ្រថ្នាក់ស្រុក ខណ្ឌ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- គ្រប់គ្រង គាំទ្រ និងសម្របសម្រួលកម្មវិធី និងគម្រោងទាំងអស់ដែលគាំទ្រ សហការ និងប្រើប្រាស់រចនាសម្ព័ន្ធ និងយន្តការថ្នាក់ស្រុក ខណ្ឌ
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមគាំទ្រ ដោយរួមបញ្ចូលសកម្មភាពទាំងអស់ដែលក្រុមគាំទ្រត្រូវអនុវត្ត និងគាំទ្រគម្រោង និងកម្មវិធីនានា
- រៀបចំកិច្ចសន្យាប្រចាំឆ្នាំរវាងក្រុមគាំទ្រថ្នាក់ស្រុក ខណ្ឌជាមួយគ.ជ.វ.វ ក្នុងការអនុវត្តផែនការសកម្មភាព និងថវិកា
- អនុវត្ត និងគ្រប់គ្រងកិច្ចសន្យាប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ដោយសហការយ៉ាងជិតស្និទ្ធជាមួយលេខាធិការដ្ឋាន និងក្រុមគាំទ្រកម្មវិធីរបស់ គ.ជ.វ.វ
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចសន្យា ស្របតាមនីតិវិធី និងតម្រូវការរបស់លេខាធិការដ្ឋាន និងក្រុមគាំទ្រកម្មវិធីរបស់ គ.ជ.វ.វ
- សម្របសម្រួល និងសហការយ៉ាងជិតស្និទ្ធជាមួយលេខាធិការដ្ឋាន និងក្រុមគាំទ្រកម្មវិធីរបស់ គ.ជ.វ.វ
- គាំទ្រ និងសហការជិតស្និទ្ធជាមួយគម្រោង និងកម្មវិធីនានាដែលប្រើប្រាស់រចនាសម្ព័ន្ធ យន្តការ ដំណើរការ និងនីតិវិធីសម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍

- សហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដែលពាក់ព័ន្ធនឹងគម្រោង និងកម្មវិធីគាំទ្រថ្នាក់ស្រុក ខណ្ឌ
- សហការ និងសម្របសម្រួលជាមួយកម្មវិធី ឬគម្រោងផ្សេងៗទៀតដែលពាក់ព័ន្ធ
- ជាសេនាធិការអោយអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងលេខាធិការដ្ឋាន គ.ជ.វ.វ ក្នុងការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានផ្សេងៗ ដែលពាក់ព័ន្ធនឹងកំណែទម្រង់នៅថ្នាក់ស្រុក ខណ្ឌ
- ចុះសិក្សាស្រាវជ្រាវ និងរៀបចំជាសេចក្តីណែនាំផ្សេងៗ ដែលពាក់ព័ន្ធនឹងការរៀបចំ និងអនុវត្តគម្រោង និងកម្មវិធីពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌ និងគម្រោងអន្តរឃុំ សង្កាត់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធទាំងអស់
- សិក្សា និងវាយតម្លៃការអនុវត្តគម្រោង និងកម្មវិធី និងរៀបចំជារបាយការណ៍ដែលរួមបញ្ចូលអនុសាសន៍នានាសម្រាប់ក្រសួងមហាផ្ទៃ និង គ.ជ.វ.វ ដើម្បីពិនិត្យ និងពិចារណាក្នុងការកែសម្រួល និងរៀបចំឡើងវិញនូវវចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលថ្នាក់ស្រុក ខណ្ឌក្នុងការចូលរួមចំណែកអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ
- រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងផ្សព្វផ្សាយពីសេចក្តីណែនាំផ្សេងៗដល់មន្ត្រីថ្នាក់ខេត្ត ក្រុង និងស្រុក ខណ្ឌ ដែលពាក់ព័ន្ធនឹងគម្រោង និងកម្មវិធីគាំទ្រថ្នាក់ស្រុក ខណ្ឌ
- ចុះមូលដ្ឋានជាប្រចាំ ដើម្បីត្រួតពិនិត្យតាមដាន និងគាំទ្រដល់ថ្នាក់ខេត្ត ក្រុង និងស្រុក ខណ្ឌ ក្នុងការអនុវត្តគម្រោង និងកម្មវិធីដែលគាំទ្រថ្នាក់ស្រុក ខណ្ឌ
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ និងលេខាធិកាដ្ឋាន គ.ជ.វ.វ ។

**ប្រការ៣.-**

ការបែងចែកភារកិច្ចជាក់ស្តែងដល់សមាជិកក្រុមការងារនីមួយៗ នឹងត្រូវសម្រេចដោយសេចក្តីសម្រេចរបស់ប្រធានក្រុមគាំទ្រថ្នាក់ស្រុក ខណ្ឌ ។

**ប្រការ៤.-**

ក្រសួង ស្ថាប័នជាសមាជិក គ.ជ.វ.វ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ លេខាធិការដ្ឋានគ.ជ.វ.វ ក្រុមគាំទ្រកម្មវិធីគ.ជ.វ.វ និងឯកឧត្តម អស់លោក ដែលមានឈ្មោះនៅក្នុងប្រការ១ខាងលើនេះ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.វ.វ**

ស ខេង

**កន្លែងទទួល :**
- ក្រសួងសមាជិក គ.ជ.វ.វ
- គណៈកម្មការប្រតិបត្តិគ្រប់ខេត្ត ក្រុង
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដៃគូអភិវឌ្ឍ

"ដើម្បីជូនជ្រាប"
- ដូចប្រការ ៤ (ដើម្បីអនុវត្ត)
- ឯកសារ - កាលប្បវត្តិ